ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ១៣២៦
ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ ២០០
ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤
សាលក្រមលេខ ១១ "ថ"/៣៣១
ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការជាសាធារណៈ | ៖ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ |
| សាលសវនាការ និងពេលវេលា | ៖ សាល ខ១ ពេល រសៀល |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ |
| សាលសវនាការ និងពេលវេលា | ៖ សាល ខ១ ពេល ព្រឹក |

ក្រោមសមាសភាពជំនុំជម្រះ

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ឋានៈជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីធ្វើការពិភាក្សាដេញដោលលើ

សំណុំរឿងព្រហ្មទណ្ឌលេខ ១៣២៦ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ស៊ីលៀប ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប មុខរបរមេផ្ទះ កម្រិតវប្បធម៌ ថ្នាក់ទី០៣ ឪពុកឈ្មោះ [redacted] ចាន់ធឿន (រ) ម្តាយឈ្មោះ [redacted] គីមសេង (រ) ប្តីឈ្មោះ [redacted] សម្បត្តិ មានកូន០១នាក់ ។ (គ្មានខ្លួន)

ជាប់ចោទពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅក្នុងបណ្តាញសង្គមហ្វេសប៊ុក (Facebook) កាលពីអំឡុងខែធ្នូ ឆ្នាំ២០២៣ ដល់អំឡុងខែមករា ឆ្នាំ២០២៤ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ជួន ស៊ីលៀប ។



Scanned with CamScanner

## អង្គហេតុកើតឡើងមានដូចតទៅ

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ ស្ថិតនៅលើបណ្ដាញសង្គមហ្វេសប៊ុក (Facebook) មានឈ្មោះ [redacted] គឹមសេង ភេទស្រី អាយុ៥១ឆ្នាំ បានប្រើប្រាស់គណនីហ្វេសប៊ុកឈ្មោះ [redacted] សេង បង្ហោះជាសាធារណៈនូវរូបថតរបស់ឈ្មោះ [redacted] ពិសិដ្ឋ ភេទស្រី និងប្ដី ដោយមានភ្ជាប់នូវខ្លឹមសារ "មីអ្នកមានចេញមុខមកសងលុយអញផង អញគ្មានលុយទេ ទាំងលុយខ្ចីទាំងលុយថ្លៃផ្ទះអញផង លួចរបស់ក្នុងផ្ទះអញទៀតមីនេះជំពាក់លុយគេហើយខ្លាំងទៀតជួយShare អោយមីអ្នកមានឃើញផង.." ហើយឈ្មោះ [redacted] ស៊ីលៀប ភេទស្រី បានប្រើប្រាស់គណនីហ្វេសប៊ុកឈ្មោះ [redacted] លាភ ចែករំលែកបន្ត (Share) ជាសាធារណៈនូវរូបថតខាងលើភ្ជាប់ជាមួយនឹងខ្លឹមសារ "សងលុយអញផង PISETH កុំចោកទាបពេកទាំងលុយខ្ចីទាំងលុយលួចទាំងលុយថ្លៃជួលផ្ទះ PU Nath" ។ លុះដល់ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៤ គណនីហ្វេសប៊ុកឈ្មោះ [redacted] លាភ ក៏បានបង្ហោះផ្សាយជាសាធារណៈបន្ថែម ដែលមានខ្លឹមសារថា "ដំណឹងរំលឹកបន្ទាន់ សូមអ្នកទាំងអស់គ្នាប្រុងប្រយ័ត្ន! មនុស្សពីរនាក់ប្ដីប្រពន្ធនេះខ្ចីលុយមិនសងជួលផ្ទះ មិនបង់លុយបីខែជាងដើម្បីកុំឲ្យមាននៅជនរងគ្រោះបន្ទាប់! ដូច្នេះសូមអ្នកទាំងអស់គ្នាជួយស៊ែរចែករំលែកបន្តផង ដើម្បីកុំឲ្យមាននៅជនរងគ្រោះបន្តទៀតអោយមកដោះស្រាយមិនមកទៀត ចោកទាបរកលេខដាក់គ្នាន បានជួបមុខនៅណាដាក់ឲ្យខ្មាសគេម្ដងលុយសរុប 600$ ជាងកម្លាំងញើសឈាមរបស់ខ្ញុំ" ។ ផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] គឹមសេង និងឈ្មោះ [redacted] ស៊ីលៀប បានបញ្ជាក់ថា ពួកគេពិតជាបានប្រើប្រាស់គណនីហ្វេសប៊ុកខាងលើ និងធ្វើសកម្មភាពបង្ហោះព្រមទាំងចែករំលែកបន្ត (Share) ដូចរៀបរាប់ខាងលើប្រាកដមែន ។

## ដើមបណ្ដឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] ពិសិដ្ឋ ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ទីកន្លែងកំណើតនៅឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិអូរពឹត សង្កាត់ទួលល្វា ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។

បានឃើញ ៖ ពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ពិសិដ្ឋ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ ។

បានឃើញ ៖ ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ៥១៩ អយណ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ៖ ដីកាចាត់តាំងចៅក្រមជំនុំជម្រះផ្ទាល់លេខ ២២៣ ដកចត/២៤(ក) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

- អំណានចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ស៊ីលៀប នៅដំណាក់កាលអយ្យការបានឆ្លើយថា ៖ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ខ្លួនបានជួលផ្ទះមួយកន្លែងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានទំហំ ២០មx២០ម = ៤០០ម៉ែត្រការ៉េ ផ្ទះទំហំ ៧,៥មx១២ម ទៅឱ្យលោក [redacted] រស្មី និងប្រពន្ធ ។ ដោយរយៈពេលនៃកិច្ចសន្យាជួលផ្ទះនេះមានចំនួន ០១ (មួយ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ តម្លៃនៃការជួលក្នុងមួយខែចំនួន ១៥០ ដុល្លារ (មួយរយហាសិបដុល្លារអាមេរិក) ដោយមិនបញ្ចូលថ្លៃប្រើប្រាស់ទឹក ភ្លើង ទូរស័ព្ទ ខ្សែកាប អ៊ីនធើណេត នោះឡើយ ។ បន្ទាប់មកឈ្មោះ [redacted] រស្មី និងប្រពន្ធ បានធ្វើការរស់នៅលើផ្ទះដែលបានជួលពីខ្លួន ចាប់តាំងពីខែមេសា រហូតមកដល់ត្រឹមខែតុលា ឆ្នាំ២០២៣ ហើយចំពោះការរស់នៅអស់



Scanned with CamScanner

ជាច្រើនខែមកនោះ ឈ្មោះ [redacted] ស្មើ និងប្រពន្ធ បានបង់ថ្លៃឈ្នួលជួលផ្ទះបានតែចំនួន ០៣ (បី) ខែ តែប៉ុណ្ណោះ និងនៅខ្វះចំនួន ០៣ (បី) ខែ ទៀត ឈ្មោះ [redacted] ស្មើ និងប្រពន្ធ ពុំបានធ្វើការទូទាត់ថ្លៃឈ្នួលផ្ទះមកឱ្យខ្លួននោះទេ ម្យ៉ាងវិញទៀត ចំពោះការទូទាត់ថ្លៃភ្លើង ឈ្មោះ [redacted] ស្មើ ពុំបានទូទាត់នោះឡើយ បែរជាទុកឱ្យជាម្ចាស់ផ្ទះទូទាត់ជំនួសអស់ចំនួន ១៩០.៦០០៛ (ដប់ប្រាំបួនម៉ឺនប្រាំមួយរយរៀល) ។ ហើយនៅពេលរើចេញពីផ្ទះខ្លួនទៅ ឈ្មោះ [redacted] ពិសិដ្ឋ និងប្រពន្ធ បានយកចានឆ្នាំង ធុងហ្គាស និងប្រាក់យ័ន្តចំនួនដប់ម៉ឺនរៀល ។ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ និងថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៣ ឈ្មោះ [redacted] ពិសិដ្ឋ ដែលត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] ស្មើ បានមកធ្វើការខ្ចីប្រាក់ពីខ្លួនសរុបចំនួន ១០០$ ហើយបានសងត្រលប់មកវិញបានតែចំនួន ៥០$ នោះទេដោយនៅខ្វះចំនួន ៥០$ ទៀត ។ ចំពោះឈ្មោះ [redacted] ស្មើ និងប្រពន្ធឈ្មោះ [redacted] ពិសិដ្ឋ ពួកគេតែងតែសុំពន្យារពេលបង់ប្រាក់ជាច្រើនដង និងច្រើនខែ ហើយសន្យាថាបង់ថ្ងៃនេះថ្ងៃនោះរហូត ប៉ុន្តែជាក់ស្តែងដល់ថ្ងៃដែលពួកគេសន្យាពួកគេតែងតែគេចវេសមិនព្រមធ្វើការទូទាត់ថ្លៃឈ្នួល និងប្រាក់ជំពាក់នោះទេ ។ ខ្លួនជាម្ចាស់ផ្ទះបានដាក់ពាក្យបណ្តឹងទៅលោកមេភូមិ និង លោកមេប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ស្រង៉ែ ដើម្បីឱ្យជួយដោះស្រាយ និងជូនដំណឹងទៅបុគ្គលឈ្មោះ [redacted] ស្មើ និងប្រពន្ធឈ្មោះ [redacted] ពិសិដ្ឋ តាមរយៈទូរស័ព្ទ ឱ្យមកធ្វើការទូទាត់ប្រាក់សងប្រាក់ដែលបានជំពាក់មកឱ្យខ្លួនវិញ ប៉ុន្តែបើទោះបីជាលោកមេភូមិ និងលោកមេប៉ុស្តិ៍ និងនគរបាលរដ្ឋបាលសង្កាត់ស្រង៉ែ ហៅបុគ្គលទាំងពីរនាក់ខាងលើមក ដោះស្រាយយ៉ាងណាក៏ដោយ ក៏ពួកគេមិនព្រមចូលខ្លួនមកដោះស្រាយនោះដែរ ថែមទាំងគេចវេសមិនព្រមសងថែមទៀតផង ។ ខ្លួនសូមបញ្ជាក់ថាខ្លួនទទួលស្គាល់ថាពិតជាបានប្រើប្រាស់គណនីហ្វេសប៊ុក ឈ្មោះ [redacted] លាភ ដោយបានចែករំលែកការបង្ហោះសារដែលមានខ្លឹមសារថា "មីអ្នកមានចេញមុខមកសង លុយអញផង អញគ្មានលុយទេ ទាំងលុយខ្ចី ទាំងលុយថ្លៃផ្ទះអញផង លួចរបស់ក្នុងផ្ទះអញទៀតមីនេះ ជំពាក់លុយគេហើយខ្លាំងទៀត ជួយ Share អោយមីអ្នកមានឃើញផង" ប្រាកដមែន ។

- អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅដំណាក់កាលអយ្យការថា ៖ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ខ្លួនបានជួលផ្ទះមួយកន្លែងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ពីឈ្មោះ អាលាភ និងឈ្មោះ គឹមសេង ដោយរយៈពេលនៃកិច្ចសន្យាជួលផ្ទះនេះមានចំនួន ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ តម្លៃនៃការជួលក្នុងមួយខែចំនួន ១៥០ ដុល្លារ (មួយរយហាសិបដុល្លារអាមេរិក)ដោយមិនបញ្ចូលថ្លៃប្រើប្រាស់ទឹក ភ្លើង ទូរស័ព្ទ ខ្សែកាប អ៊ីនធើណេត នោះឡើយ ។ បន្ទាប់ពីជួលផ្ទះខាងលើគឺខ្លួនបានបង់ប្រាក់ចំនួន ៤ខែ ប៉ុន្តែបានអាក់ខានបង់ចំនួន ២ខែ នៅក្នុងខែ សីហា និងខែកញ្ញា នៅក្នុងអំឡុងឆ្នាំ២០២៣ ខ្លួន និងប្តីឈ្មោះ [redacted] ស្មើ បានខ្ចីប្រាក់ពីឈ្មោះ អាលាភ ចំនួន ៥០$ នៅពេលកូនខ្លួនឈឺ ហើយមិនទាន់បានសងប្រាក់ទៅឈ្មោះ អាលាភ វិញនោះទេ ។ រីឯប្រាក់ថ្លៃបង់ភ្លើងគឺខ្លួនមិនទាន់បានបង់នោះទេ ហើយខ្លួនក៏បានសុំពន្យារពេលបង់ប្រាក់ជាច្រើនដង ប៉ុន្តែជាក់ស្តែងខ្លួនមិនទាន់មានប្រាក់បង់ឱ្យគាត់ ។ ឈ្មោះ អាលាភ បានប្រាប់ឱ្យចៅសង្កាត់ និងមេភូមិ ទៅរើអីវ៉ាន់ខ្លួនមកទុកនៅផ្ទះរបស់មេភូមិ ហើយមានអ្នកជិតខាង មកទាក់ទងមកខ្លួនប្រាប់ថា គេរើអីវ៉ាន់ខ្លួនអស់ហើយ ។ បន្ទាប់មកចៅសង្កាត់បានទាក់ទងមកខ្លួន ដើម្បីឱ្យមកដោះស្រាយគ្នាបើទោះបីអត់មានលុយក៏ដោយចាំគាត់ជួយសម្រួល ប៉ុន្តែឈ្មោះ អាលាភ មិនព្រមដោះស្រាយជាមួយទេ ក៏បានឱ្យម្តាយមីងមកជំនួសដោយនៅតែទាមទារថ្លៃផ្ទះ ថ្លៃភ្លើង ថ្លៃជួសជុលផ្ទះគាត់ និងប្រាក់ខ្ចីចំនួន ៥០$ ដុល្លារអាមេរិក ព្រមទាំងថាខ្លួនបានលួចប្រាក់របស់គាត់ ។



Scanned with CamScanner

បន្ទាប់មកដោះស្រាយគ្នាមិនបាន ប្ដីខ្លួនក៏បានត្រឡប់មកវិញ ក៏ស្រាប់តែម្ដាយមីងរបស់ឈ្មោះ អាលាភ បានថតវីដេអូ និងនិយាយថាប្ដីខ្លួនជាជនបោក និងពាក្យសំដីជាច្រើនទៀត ។ ក្រោយមកទៀត ឈ្មោះ គីមសេង បានប្រើអាខោនហ្វេសប៊ុករបស់គាត់ឈ្មោះ "គីមសេង" បានផុសរូបខ្លួន និងគ្រួសារដោយបាន សរសេរបង្ហោះសារដែលមានខ្លឹមសារថា "មីអ្នកមាន ចេញមុខមកសងលុយអញផង អញគ្មានលុយទេ ទាំងលុយខ្ចី ទាំងលុយថ្លៃផ្ទះអញផង លួចរបស់ក្នុងផ្ទះអញទៀតមីនេះ ជំពាក់លុយគេហើយខ្លាំងទៀត ជួយ Share អោយមីអ្នកមានឃើញផង" ហើយឈ្មោះ អាលាភ ក៏បានចែករំលែកសារនោះផងដែរ ដោយ ខ្លួនមានវីដេអូដែលមានខ្លឹមសារជេរប្រមាថប្ដីខ្លួនទៀតផង ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] គីមសេង បានឆ្លើយថា ៖ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០២៣ ខ្លួនបានជួលផ្ទះមួយកន្លែងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ដែល មានទំហំ ២០មx២០ម = ៤០០ម៉ែត្រការ៉េ ផ្ទះទំហំ ៧.៥មx១២ម ទៅឱ្យលោក [redacted] រស្មី និងប្រពន្ធ ។ ដោយរយៈពេលនៃកិច្ចសន្យាជួលផ្ទះនេះមានចំនួន ០១ (មួយ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ តម្លៃនៃការជួលក្នុងមួយខែចំនួន ១៥០ ដុល្លារ (មួយរយ ហាសិបដុល្លារអាមេរិក) ដោយមិនបញ្ចូលថ្លៃប្រើប្រាស់ទឹក ភ្លើង ទូរស័ព្ទ ខ្សែកាប អ៊ីនធើណេត នោះឡើយ ។ បន្ទាប់មកឈ្មោះ [redacted] រស្មី និងប្រពន្ធ បានធ្វើការរស់នៅលើផ្ទះដែលបានជួលពីខ្លួន ចាប់តាំងពីខែមេសា រហូតមកដល់ត្រឹមខែតុលា ឆ្នាំ២០២៣ ហើយចំពោះការរស់នៅអស់ជាច្រើនខែមកនោះឈ្មោះ [redacted] រស្មី និងប្រពន្ធបានបង់ថ្លៃឈ្នួលជួលផ្ទះបានតែចំនួន ០៣ (បី) ខែ តែប៉ុណ្ណោះ និងនៅខ្វះចំនួន ៣ (បី) ខែ ទៀត ឈ្មោះ [redacted] រស្មី និងប្រពន្ធ ពុំបានធ្វើការទូទាត់ថ្លៃឈ្នួលផ្ទះមកឱ្យខ្លួននោះទេ ម្យ៉ាងវិញទៀត ចំពោះ ការទូទាត់ថ្លៃភ្លើងឈ្មោះ [redacted] រស្មី ពុំបានទូទាត់នោះឡើយ បែរជាទុកឱ្យខ្លួនជាម្ចាស់ផ្ទះទូទាត់ជំនួសអស់ ចំនួន ១៩០.៦០០ (ដប់ប្រាំបួនម៉ឺនប្រាំមួយរយរៀល) ។ ហើយនៅពេលរើចេញពីផ្ទះខ្លួនទៅឈ្មោះ [redacted] ពិសិដ្ឋ និងប្រពន្ធ បានយកចាន ឆ្នាំង ធុងហ្គាស និងប្រាក់យ័ន្ត ចំនួនដប់ម៉ឺនរៀល ។ នៅថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ២០២៣ និងថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៣ ឈ្មោះ [redacted] ពិសិដ្ឋ ដែលត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] រស្មី បានមកធ្វើការខ្ចីប្រាក់ពីខ្លួនសរុបចំនួន ១០០$ ហើយបានសងត្រលប់មកវិញបានតែចំនួន ៥០$ នោះទេ ដោយនៅខ្វះចំនួន ៥០$ ទៀត ។ ចំពោះឈ្មោះ [redacted] រស្មី និងប្រពន្ធឈ្មោះ [redacted] ពិសិដ្ឋ ពួកគេ តែងតែសុំពន្យារពេលបង់ប្រាក់ជាច្រើនដង និងច្រើនខែ ហើយសន្យាថាបង់ថ្ងៃនេះថ្ងៃនោះរហូត ប៉ុន្តែជាក់ស្ដែង ដល់ថ្ងៃដែលពួកគេសន្យា ពួកគេតែងតែគេចវេសមិនព្រមធ្វើការទូទាត់ថ្លៃឈ្នួល នឹងប្រាក់ជំពាក់នោះទេ។ ខ្លួនជាម្ចាស់ផ្ទះបានដាក់ពាក្យបណ្ដឹងទៅលោកមេភូមិ និងលោកមេប៉ុស្ដិ៍នគរបាលរដ្ឋបាលសង្កាត់ស្រង៉ែដើម្បី ឱ្យជួយដោះស្រាយ និងជូនដំណឹងទៅបុគ្គលឈ្មោះ [redacted] រស្មី និងប្រពន្ធឈ្មោះ [redacted] ពិសិដ្ឋ តាមរយៈ ទូរស័ព្ទឱ្យមកធ្វើការទូទាត់ប្រាក់សងប្រាក់ដែលបានជំពាក់មកឱ្យខ្លួនវិញ ប៉ុន្តែបើទោះបីជាលោកមេភូមិ និង លោកមេប៉ុស្ដិ៍ និងនគរបាលរដ្ឋបាលសង្កាត់ស្រង៉ែ ហៅបុគ្គលទាំងពីរនាក់ខាងលើមកដោះស្រាយយ៉ាងណា ក៏ដោយ ក៏ពួកគេមិនព្រមចូលខ្លួនមកដោះស្រាយនោះដែរ ថែមទាំងគេចវេសមិនព្រមសងថែមទៀតផង ។ ខ្លួនសូមបញ្ជាក់ថាខ្លួនទទួលស្គាល់ថា ពិតជាបានប្រើប្រាស់គណនីហ្វេសប៊ុកឈ្មោះ គីមសេង ដោយបាន ផុសបង្ហោះសារដែលមានខ្លឹមសារថា "មីអ្នកមាន ចេញមុខមកសងលុយអញផង អញគ្មានលុយទេ ទាំង លុយខ្ចី ទាំងលុយថ្លៃផ្ទះអញផង លួចរបស់ក្នុងផ្ទះ អញទៀតមីនេះ ជំពាក់លុយគេហើយខ្លាំងទៀត ជួយ Share អោយមីអ្នកមានឃើញផង" ។



Scanned with CamScanner

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិភាក្សាដេញដោលនាពេលសវនាការលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣២៦ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ភេទស្រី អាយុ៣៤ឆ្នាំ ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅក្នុងបណ្ដាញសង្គមហ្វេសប៊ុក (Facebook) កាលពីអំឡុងខែធ្នូ ឆ្នាំ២០២៣ ដល់អំឡុងខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ដោយផ្អែកតាមភស្តុតាង និងអំណានចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ឃើញថាជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយបានប្រើគណនីហ្វេសប៊ុក (Facebook) របស់ខ្លួនឈ្មោះថា អាលាភ បង្ហោះ និងចែករំលែកជាសាធារណៈនូវការបង្ហោះរបស់គណនីឈ្មោះ គីមសេង ដែលអាចឲ្យសាធារណជនមើលឃើញ និងវិលចឲ្យឃើញពាក្យជេរប្រមាថលើដើមបណ្ដឹងរដ្ឋប្បវេណី ដូច្នេះ តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហើយសុំឱ្យតុលាការតម្កល់ការចោទប្រកាន់ និងស្នើសុំចៅក្រមជំនុំជម្រះពិនិត្យសម្រេចតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ខ្ញុំបាទជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប សូមធ្វើសេចក្ដីសន្និដ្ឋានការពារ ដោយរក្សាខ្លឹមសារនៃសេចក្ដីសន្និដ្ឋានការពារលេខ ១៨១ NT/២៤ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ដែលបានដាក់ជូនតុលាការ ។ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ផ្ទាល់លេខ ៥១៩ អយឈ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ តំណាងអយ្យការបានចោទប្រកាន់លើកូនក្ដី ខ្ញុំបាទ ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅក្នុងបណ្ដាញសង្គមហ្វេសប៊ុក (Facebook) កាលពីអំឡុងខែធ្នូ ឆ្នាំ២០២៣ ដល់អំឡុងខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។ ខ្ញុំបាទសូមបញ្ជាក់ជូនចៅក្រមជំនុំជម្រះថា កូនក្ដីខ្ញុំបាទពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ផ្ទុយទៅវិញកូនក្ដីខ្ញុំបាទឈ្មោះ [redacted] ស៊ីលៀប គ្រាន់តែបានស៊ែរ (Share) បន្ត ពីការបង្ហោះ (Post) របស់ម្ដាយខ្លួនដែលទាក់ទងនឹងការជូនដំណឹងឲ្យឈ្មោះ [redacted] ពិសិដ្ឋ មកសងប្រាក់ថ្លៃឈ្នួលផ្ទះតែប៉ុណ្ណោះ ដែលអំពើរបស់កូនក្ដីខ្ញុំបាទពុំបានប្រព្រឹត្តទៅលើបុគ្គលឈ្មោះ [redacted] ពិសិដ្ឋ នោះទេ ។ កូនក្ដីខ្ញុំបាទមិនមានសកម្មភាព ឬចេតនាណាមួយដែលពាក់ព័ន្ធជាមួយនឹងបទល្មើស បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ដូចមានចែងនៅក្នុងមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ។ ដូច្នេះ សូមលោកស្រីចៅក្រមជំនុំជម្រះមេត្តាលើកលែងបទចោទប្រកាន់លើកូនក្ដីខ្ញុំបាទឈ្មោះ [redacted] ស៊ីលៀប ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និង ជេរប្រមាថជាសាធារណៈ ដែលមានចែងនៅក្នុងមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ១៣២៦ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន និងប្ដឹងសុំរបស់តំណាងអយ្យការ ។



Scanned with CamScanner

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។
-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានារបស់មន្ត្រីនគរបាលយុត្តិធម៌ ។
-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

**សំអាងហេតុ**

១. តុលាការបានទទួលជំនុំជម្រះផ្ទាល់លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣២៦ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០២៣ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ៥១៩ អយណ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មកជំនុំជម្រះផ្ទាល់ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅក្នុងបណ្ដាញសង្គមហ្វេសប៊ុក(Facebook) កាលពីអំឡុងខែធ្នូ ឆ្នាំ២០២៣ ដល់អំឡុងខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

២. តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅដំណាក់កាលអយ្យការថា កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ខ្លួនបានជួលផ្ទះមួយកន្លែងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ពីឈ្មោះ អាលាភ និងឈ្មោះ គឹមសេង ដោយរយៈពេលនៃកិច្ចសន្យាជួលផ្ទះនេះមានចំនួន ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ តម្លៃនៃការជួលក្នុងមួយខែចំនួន ១៥០ ដុល្លារ (មួយរយហាសិបដុល្លារអាមេរិក)ដោយមិនបញ្ចូលថ្លៃប្រើប្រាស់ទឹក ភ្លើង ទូរស័ព្ទ ខ្សែកាប អ៊ីនធើណេត នោះឡើយ ។ បន្ទាប់ពីជួលផ្ទះខាងលើគឺខ្លួនបានបង់ប្រាក់ចំនួន ៤ខែ ប៉ុន្តែបានអាក់ខានបង់ចំនួន ២ខែ នៅក្នុងខែ សីហា និងខែកញ្ញា នៅក្នុងអំឡុងឆ្នាំ២០២៣ ខ្លួន និងប្ដីឈ្មោះ [redacted] រស្មី បានខ្ចីប្រាក់ពីឈ្មោះ អាលាភ ចំនួន ៥០$ នៅពេលកូនខ្លួនឈឺ ហើយមិនទាន់បានសងប្រាក់ទៅឈ្មោះ អាលាភ វិញនោះទេ ។ រីឯប្រាក់ថ្លៃបង់ភ្លើងគឺខ្លួនមិនទាន់បានបង់នោះទេ ហើយខ្លួនក៏បានសុំពន្យាពេលបង់ប្រាក់ជាច្រើនដង ប៉ុន្តែជាក់ស្ដែងខ្លួនមិនទាន់មានប្រាក់បង់ឱ្យគាត់ ។ ឈ្មោះ អាលាភ បានប្រាប់ឱ្យចៅសង្កាត់ និងមេភូមិ ទៅរើអីវ៉ាន់ខ្លួនមកទុកនៅផ្ទះរបស់មេភូមិ ហើយមានអ្នកជិតខាង មកទាក់ទងមកខ្លួនប្រាប់ថា គេរើអីវ៉ាន់ខ្លួនអស់ហើយ ។ បន្ទាប់មកចៅសង្កាត់បានទាក់ទងមកខ្លួន ដើម្បីឱ្យមកដោះស្រាយគ្នាបើទោះបីអត់មានលុយក៏ដោយចាំគាត់ជួយសម្រួល ប៉ុន្តែឈ្មោះ អាលាភ មិនព្រមដោះស្រាយជាមួយទេ ក៏បានឱ្យម្ដាយមីងមកជំនួសដោយនៅតែទាមទារថ្លៃផ្ទះ ថ្លៃភ្លើង ថ្លៃជួសជុលផ្ទះគាត់ និងប្រាក់ខ្ចីចំនួន ៥០$ ដុល្លារអាមេរិក ព្រមទាំងថាខ្លួនបានលួចប្រាក់របស់គាត់ ។ បន្ទាប់មកដោះស្រាយគ្នាមិនបាន ប្ដីខ្លួនក៏បានត្រឡប់មកវិញ ក៏ស្រាប់តែម្ដាយមីងរបស់ឈ្មោះ អាលាភ បានថតវីដេអូ និងនិយាយថាប្ដីខ្លួនជាជនបោក និងពាក្យសំដីជាច្រើនទៀត ។ ក្រោយមកទៀត ឈ្មោះ គឹមសេង បានប្រើអាខោនហ្វេសប៊ុករបស់គាត់ឈ្មោះ "គឹមសេង" បានផុសរូបខ្លួន និងគ្រួសារដោយបានសរសេរបង្ហោះសារដែលមានខ្លឹមសារថា "មីអ្នកមាន ចេញមុខមកសងលុយអញផង អញគ្មានលុយទេ ទាំងលុយខ្ចី ទាំងលុយថ្លៃផ្ទះអញផង លួចរបស់ក្នុងផ្ទះអញទៀតមីនេះ ជំពាក់លុយគេហើយខ្លាំងទៀត ជួយ Share អោយមីអ្នកមានឃើញផង" ហើយឈ្មោះ អាលាភ ក៏បានចែករំលែកសារនោះផងដែរ ដោយខ្លួនមានវីដេអូដែលមានខ្លឹមសារជេរប្រមាថប្ដីខ្លួនទៀតផង ។



Scanned with CamScanner

៣. តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] គឹមសេង បានឆ្លើយនៅដំណាក់កាលអយ្យការថា ខ្លួនជាម្ចាស់ផ្ទះបានដាក់ពាក្យបណ្ដឹងទៅលោកមេភូមិ និងលោកមេប៉ុស្ដិ៍នគរបាលរដ្ឋបាលសង្កាត់ស្រង៉ែដើម្បីឱ្យជួយដោះស្រាយ និងជូនដំណឹងទៅបុគ្គលឈ្មោះ [redacted] រស្មី និងប្រពន្ធឈ្មោះ [redacted] ពិសិដ្ឋ តាមរយៈទូរស័ព្ទឱ្យមកធ្វើការទូទាត់ប្រាក់សងប្រាក់ដែលបានជំពាក់មកឱ្យខ្លួនវិញ ប៉ុន្តែបើទោះបីជាលោកមេភូមិ និងលោកមេប៉ុស្ដិ៍ និងនគរបាលរដ្ឋបាលសង្កាត់ស្រង៉ែ ហៅបុគ្គលទាំងពីរនាក់ខាងលើមកដោះស្រាយយ៉ាងណាក៏ដោយ ក៏ពួកគេមិនព្រមចូលខ្លួនមកដោះស្រាយនោះដែរ ថែមទាំងគេចវេសមិនព្រមសងថែមទៀតផង ។ ខ្លួនសូមបញ្ជាក់ថាខ្លួនទទួលស្គាល់ថា ពិតជាបានប្រើប្រាស់គណនីហ្វេសប៊ុកឈ្មោះ គឹមសេង ដោយបានផុសបង្ហោះសារដែលមានខ្លឹមសារថា "មីអ្នកមាន ចេញមុខមកសងលុយអញផង អញគ្មានលុយទេ ទាំងលុយខ្ចី ទាំងលុយថ្លៃផ្ទះអញផង លួចរបស់ក្នុងផ្ទះ អញទៀតមីនេះ ជំពាក់លុយគេហើយខ្លាំងទៀត ជួយ Share អោយមីអ្នកមានឃើញផង" ។ ចម្លើយរបស់សាក្សីឈ្មោះ [redacted] គឹមសេង គឺជាចម្លើយមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងភស្តុតាងនានាក្នុងសំណុំរឿង ។

៤. តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប បានឆ្លើយនៅដំណាក់កាលអយ្យការថា ខ្លួនទទួលស្គាល់ថាពិតជាបានប្រើប្រាស់គណនីហ្វេសប៊ុកឈ្មោះ អា លាភ ដោយបានចែករំលែកការបង្ហោះសារដែលមានខ្លឹមសារថា "មីអ្នកមាន ចេញមុខមកសង លុយអញផង អញគ្មានលុយទេ ទាំងលុយខ្ចី ទាំងលុយថ្លៃផ្ទះអញផង លួចរបស់ក្នុងផ្ទះអញទៀតមីនេះ ជំពាក់លុយគេហើយខ្លាំងទៀត ជួយ Share អោយមីអ្នកមានឃើញផង" ប្រាកដមែន ។ ចម្លើយរបស់ជនជាប់ចោទ ជាចម្លើយមានភាពស៊ីសង្វាក់នឹងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយរបស់សាក្សី និងភស្តុតាងនានាក្នុងសំណុំរឿង ។

៥. ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ ចម្លើយរបស់សាក្សីឈ្មោះ [redacted] គឹមសេង ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប និងភស្តុតាងក្នុងសំណុំរឿង ពិនិត្យឃើញថាខ្លឹមសារដែលជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប បានបង្ហោះមានចរិតលក្ខណៈជាការអះអាងបំផ្លើស ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ ដោយបានអះអាងថាឈ្មោះ [redacted] ពិសិដ្ឋ បាន លួចលុយ ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប នៅដំណាក់កាលអយ្យការ បានឆ្លើយថា "នៅពេលរើចេញពីផ្ទះខ្លួនទៅ ឈ្មោះ [redacted] ពិសិដ្ឋ និងប្រពន្ធ បានយកចានឆ្នាំងធុងហ្គាស និងប្រាក់យ័ន្ត ចំនួនដប់ម៉ឺនរៀល ។" ដោយឡែក តាមការពិនិត្យភស្តុតាងជនជាប់ចោទឈ្មោះ ជួន ស៊ីលៀប បានប្រើប្រាស់គណនីហ្វេសប៊ុករបស់ខ្លួនឈ្មោះ អា លាភ ចែករំលែកបន្ត (Share) ការបង្ហោះ (Post) របស់គណនីហ្វេសប៊ុកឈ្មោះ [redacted] សេង និងបានបង្ហោះជាសាធារណៈភ្ជាប់នូវខ្លឹមសារថា "សងលុយ ផង PI SETH កុំថោកទាបពេកទាំងលុយខ្ចីទាំងលុយលួចទាំងលុយថ្លៃជួលផ្ទះ PU Nath" ។ ការបង្ហោះជាសាធារណៈនេះ ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ពុំបានបញ្ជាក់ថាជាលុយយ័ន្តដូចចម្លើយដែលបានឆ្លើយនៅដំណាក់កាលអយ្យការនោះឡើយ ហើយផ្អែកតាមភស្តុតាងជាបញ្ជីឈ្មោះសម្ភារៈក្នុងផ្ទះ ក៏ពិនិត្យឃើញថាពុំមានសរសេរបញ្ជាក់ថាមានលុយយ័ន្តនោះដែរ ។ ដូច្នេះ ការបង្ហោះ និងចែកចាយបន្តជាសាធារណៈរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប នូវខ្លឹមសារថាឈ្មោះ [redacted] ពិសិដ្ឋ បាន លួចលុយ គឺមានចេតនាអះអាងដោយបំផ្លើស ដើម្បីនាំឲ្យមានការភ័ន្តច្រលំថាឈ្មោះ [redacted] ពិសិដ្ឋ ពិតជាបានលួចប្រាក់ខ្លួនប្រាកដមែន ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ ។



Scanned with CamScanner

៦. ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ ចម្លើយរបស់សាក្សីឈ្មោះ [redacted] គឹមសេង ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប និងភស្តុតាងក្នុងសំណុំរឿង ពិនិត្យឃើញថា ខ្លឹមសារដែលជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប បានបង្ហោះជាសាធារណៈនៅក្នុងគណនីហ្វេសប៊ុករបស់ខ្លួនឈ្មោះ អា លាភ មានការបញ្ចេញពាក្យពេចន៍មិនសមរម្យ ដូចជាការប្រើប្រាស់ពាក្យថា "ចោកទាប រកលេខដាក់គ្មានបានជួបមុខនៅណាដាក់អោយខ្ទាស់គេម្តង" ។

៧. សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប បានធ្វើសកម្មភាពបង្ហោះនៅក្នុងបណ្តាញសង្គមហ្វេសប៊ុកជាសាធារណៈ ដោយការអះអាងបំផ្លើស ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានច្បាប់កំណត់ថាជាបទល្មើស បរិហារកេរ្តិ៍ជាសាធារណៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

៨. សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប បានធ្វើសកម្មភាពបង្ហោះនៅក្នុងបណ្តាញសង្គមហ្វេសប៊ុកជាសាធារណៈ ដោយការប្រើពាក្យប្រមាថមើលងាយលើដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានច្បាប់កំណត់ថាជាបទល្មើស ជេរប្រមាថជាសាធារណៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៧ ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

៩. អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ធ្វើឱ្យប៉ះពាល់ដល់បុគ្គលភាពអ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយក្នុងសង្គម ដែលច្បាប់ហាមឃាត់ ជាពិសេសបានបំពានទៅនឹងមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

១០. ជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ជានីតិជន ដែលមានសមត្ថភាព ស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

១១. មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅក្នុងបណ្តាញសង្គមហ្វេសប៊ុក(Facebook) កាលពីអំឡុងខែធ្នូ ឆ្នាំ២០២៣ ដល់អំឡុងខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

១២. តំណាងអយ្យការនាពេលសវនាការបានសន្និដ្ឋានដាក់បន្ទុក កំណត់ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ដោយស្នើសុំតម្កល់ការចោទប្រកាន់ និងស្នើសុំទៅក្រុមជំនុំជម្រះពិនិត្យសម្រេចតាមច្បាប់ ។

១៣. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល ដោយការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើន គប្បីតុលាការសម្រេចបន្ធូរបន្ថយឲ្យបានសមស្របទៅនឹងទំហំនៃព្យសនកម្ម និងស្ថានភាពជីវភាពរបស់ជនជាប់ចោទ ។

## ហេតុដូច្នេះសម្រេច

**១.ផ្តន្ទាទោស ៖**

ឈ្មោះ [redacted] ស៊ីលៀប ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដោយពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។



Scanned with CamScanner

ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ និងជេរប្រមាថជាសាធារណៈ ប្រព្រឹត្តនៅក្នុងបណ្តាញសង្គម ហ្វេសប៊ុក (Facebook) កាលពីអំឡុងខែធ្នូ ឆ្នាំ២០២៣ ដល់អំឡុងខែមករា ឆ្នាំ២០២៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣០៥ និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

២. បង្គាប់ឲ្យឈ្មោះ [redacted] ស៊ីលៀប សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥០០.០០០ (ហាសិបម៉ឺន) រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ស៊ីលៀប និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជម្រះ** [redacted]